ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៧ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I . ទីស្ដីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

១៨–៧–១៩៩៦– អនុក្រឹត្យលេខ ៣៥ អនក្រ . បក ស្ដីពីការបែងចែកជំពូកចំណាយឥតគ្រោងទុក នៃថវិការដ្ឋ ឆ្នាំ ១៩៩៦ ១១៧៨
២៣–៧–១៩៩៦ – អនុក្រឹត្យលេខ ១៣១ អនក្រ. គត ស្ដីពីការជូនមេដាយសហមេត្រី ១១៧៩

២-សេចក្ដីសំរេច

២៣–៧–១៩៩៦ – សេចក្ដីសំរេចលេខ ២៩ សសរ ស្ដីពីការផ្ទេរសិទ្ធិ ១១៨១

II - ការិយាល័យបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១៨–៧–១៩៩៦ – ប្រកាសលេខ ២៥៥ នបប្រក. សហវ ស្ដីពីការផ្លាស់ប្ដូរមន្ត្រីរាជការគយ និងរដ្ឋាករ នៃការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ ១១៨២
១៨–៧–១៩៩៦ – ប្រកាសលេខ ២៥៦ នបប្រក. សហវ ស្ដីពីការបង្កើតក្រុមការងារអាស៊ាន អមទីចាត់ការគយ និងរដ្ឋាករ ១១៨៥
១៨–៧–១៩៩៦ – ប្រកាសលេខ ២៥៧ ប្រក. សហវ. គរ ស្ដីពីការគ្រប់គ្រងលើទំនិញនាំចេញ ១១៩០
១៨–៧–១៩៩៦ – ប្រកាសលេខ ២៥៨ ប្រក. សហវ. គរ ស្ដីពីការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញ និងនាំចូលតាមកុងតឺន័រ « CONTAINER» ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យគ្រប់គ្រងផែស្ងួត

និងឃ្លាំង ដែលគ្រប់គ្រងដោយគយ និងទីលានបញ្ចេញទំនិញពីគយ និង រដ្ឋាករ ១១៩៣

២២-៧-១៩៩៦ - ប្រកាសលេខ ២៥៩ ប្រក.សហវ.ពដ ស្តីពីការរៀបចំអោយមានផ្នែកកំណត់មូលដ្ឋានគិតពន្ធ និងផ្នែកប្រមូលពន្ធនៅក្នុងសាខាពន្ធដារ ខេត្ត-ក្រុង ១១៩៦

២២-៧-១៩៩៦ - ប្រកាសលេខ ២៦២ នបប្រក.សហវ ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការ គណនេយ្យករគយ និងរដ្ឋាករ ១២០០

២៣-៧-១៩៩៦ - ប្រកាសលេខ ១១១ ប្រក.សហវ.រជ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការរតនាគារក្រុងព្រះសីហនុ ១២០៣

២៣-៧-១៩៩៦ - ប្រកាសលេខ ១១២ ប្រក.សហវ.ប ស្តីពីការបង្កើតនាយកដ្ឋានអាស៊ានបណ្តោះអាសន្ន ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១២០៤

២៣-៧-១៩៩៦ - ប្រកាសលេខ ១១៤ ប្រក.សហវ.ប ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ១២០៥

២៣-៧-១៩៩៦ - ប្រកាសលេខ ១១៥ ប្រក.សហវ.ប ស្តីពីការតែងតាំងមន្ត្រីរាជការ ១២០៧

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៤ ផក.ប្រក អនុញ្ញាតអោយលោក **គង់ សុគន្ធ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់សហគ្រាសកម្មផលិតសំភារៈអាលុយមីញ៉ូមសញ្ញា «ផ្កាយបី» ផ្ទេរសិទ្ធិគ្រប់គ្រងជូនទៅលោក ទិញ ៖ការ វិញ ១២០៨

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ហែម ម៉ុណ្ណា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងជាងផលិតគ្រឿងសង្ហារឹម ១២០៨

ឥ

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៦ ផក.ប្រក អនុញ្ញាតអោយលោក **គៀង អៀងឡុ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតកាហ្វេ តែ «**គៀង ស៊ុនហួត**» ១២០៩

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៧ ផក.ប្រក អនុញ្ញាតអោយលោក **ហេង លី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្ម ផលិតទ្វារ អាលុយមីញ៉ូម ១២១០

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៨ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ឃិន ទិចិត្រ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការ ឧស្សាហកម្មតូចផលិតសំឡីអនាម័យ និងក្រដាសអនាម័យ «សុខភាព» ១២១០

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៦៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ឃិន ទិចិត្រ** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិត ចានឆ្នាំង អំពីអាលុយមីញ៉ូមទន់ ១២១១

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៧០ ផក.ប្រក អនុញ្ញាតអោយលោក **ចាយ ស៊ាងអ៊ី** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតស្រាកែច្នៃ សញ្ញា «ដើមក្រវាញ» ១២១១

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៧១ ផក.ប្រក អនុញ្ញាតអោយលោក **ឈុត ណរិបផាន់** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា ប្តូរទីតាំង និងប្តូរឈ្មោះពីសិប្បកម្មស្រាកែច្នៃ សញ្ញា «ប្រទាលក្រុងសិរិទ្ធិ» មកជា សហគ្រាសដំបងដែកផលិតស្រាកែច្នៃ សញ្ញា «ប្រទាលក្រុងសិរិទ្ធ» វិញ ១២១២

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៧២ ផក.ប្រក អនុញ្ញាតអោយលោក **ឡា ឡៀង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទឹកស៊ីរ៉ូ សញ្ញា «ផ្លែម្នាស់» ១២១៣

១៧-៧-១៩៩៦ - ប្រកាសលេខ ៤៧៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ឃឹម សុផល** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ

កំលាំង ២៤ សេះ ១២១៤
១៨-៧-១៩៩៦ - ប្រកាសលេខ ៤៧៤ ផក.ប្រក អនុញ្ញាតអោយលោក **អៀង សុខហាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ១២១៤
១៨-៧-១៩៩៦ - ប្រកាសលេខ ៤៧៥ ផក.ប្រក អនុញ្ញាតអោយលោក **សោម សុវណ្ណ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់សិប្បកម្មផលិតទឹកបរិសុទ្ធ សញ្ញា «ត្បូង» និងទឹកកកអនាម័យ ផ្ទេរសិទ្ធិគ្រប់គ្រងជូនអ្នកស្រី **សុខ ធាន** វិញ ។ ១២១៥
១៨-៧-១៩៩៦ - ប្រកាសលេខ ៤៧៦ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី **ឡុង ចាំ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥០ សេះ ១២១៥
១៩-៧-១៩៩៦ - ប្រកាសលេខ ៤៧៧ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន អ៊ីវិន អ៊ិនធឺណាស់ស្យុងណាល់ ធូប៉ែកខូ ខូអិលធីឌី (EVAN'S INTERNA TIONAL TOBACCO Co.LTD) តំណាងដោយលោក HUYNH HOA BANG សញ្ជាតិអាមេរិកាំង បង្កើតរោងចក្រ ផលិតបារីនាំចេញ ១២១៦

៣-ឧិស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សារាចរ

២៣-៧-១៩៩៦ - សារាចរលេខ ០០២ ស.រ អនុវត្តច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង ១២១៧

៤-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

១៧-៧-១៩៩៦ - ប្រកាសលេខ ២២៨/៩៦ ពម.បសទ.ប្រក អនុញ្ញាតជូនអ្នកស្រី
អ៊ុត សុផល បើកអាជីវកម្មរោងពុម្ពឈ្មោះ «សុផល» ១២២០
១៩-៧-១៩៩៦ - ប្រកាសលេខ ២២៩ ពម.បសទ.ប្រក អនុញ្ញាតលោក **ឃុន ហាំង**
ប្រធានក្រុមហ៊ុនសាជីវកម្មផ្សព្វផ្សាយកម្ពុជា បើកស្ថានីយ៍ទូរទស្សន៍
កាណាល់លេខ ៩ ១២២១

៥-ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

២៣-៧-១៩៩៦- ប្រកាសលេខ ៦៦០ អយក.ប្រក ស្ដីពីការអនុញ្ញាតអោយបោះពុម្ព
សៀវភៅសំរាប់សិស្ស «សិក្សាសង្គមថ្នាក់ទី ៦» ១២២២

៦-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

២២-៧-១៩៩៦ - ប្រកាសលេខ ២៩៧ ប្រក.សកប ស្ដីពីការបើកការិយាល័យ
អាស៊ាន (ASEAN UNIT) ១២២៤

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ៣៥ អនក្រ.បក

ស្តីពីការបែងចែកជំពូកចំណាយឥតគ្រោងទុក នៃ ថវិការដ្ឋឆ្នាំ ១៩៩៦

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១.- អនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋ ចំនួន ២.៩៧២.៥០០.០០០ រៀល (ពីរពាន់ប្រាំបួនរយចិតសិបពីរលានប្រាំរយពាន់រៀលគត់) បញ្ចូលទៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូចៗ) របស់ក្រសួងអប់រំយុវជន និងកីឡា ។

មាត្រា ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ : ១៣១ អនក្រ.តត

ស្តីពីការដូនមេដាយសហមេត្រី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- **បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤**

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិនិងនាយអគ្គសេនាធិការកងយោធពល ខេមរភូមិន្ទ

សំរេច

មាត្រា ១.~ ត្រូវបានប្រគល់មេដាយ ធិបឌិន្ទ សហមេត្រីជូនចំពោះលោក ឧត្ដមសេនីយ៍ **ប្រាបូវូ ស៊ូប៊ីអានតូ** (PRABOWO SUBIANTO) មេបញ្ជាការទ័ពពិសេស នៃកងទ័ពឥណ្ឌូនេស៊ី ដែលមានស្នាដៃ និងគុណបំណាច់ខ្ពង់ខ្ពស់ ក្នុងការជួយឧបត្ថម្ភហ្វឹកហ្វឺន និង បណ្ដុះបណ្ដាលមុខជំនាញទ័ពពិសេសកុម្មង់ដូឆ័ត្រយោងដល់កងយោធពល ខេមរភូមិន្ទ ។

មាត្រា ២.~ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្ដលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_សេចក្ដីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

សេចក្ដីសំរេច លេខ : ២៩ សសរ
ស្ដីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១.~ ផ្ទេរសិទ្ធិជូនឯកឧត្ដម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជារដ្ឋមន្ត្រីស្ដីទី នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្នុងឱកាសដែលឯកឧត្ដមរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃក្រសួងនេះ ត្រូវអញ្ជើញទៅចូលរួមប្រជុំអាស៊ាននៅទីក្រុង Jakarta ប្រទេសឥណ្ឌូណេស៊ី ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

ប្រការ ២.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម យូ ហុកគ្រី ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១

ព្រះហស្តលេខា និង ត្រា

នរោត្តម រណឫទ្ធិ

* * *

II - ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ២៥៥ សបប្រក.សហវ

ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការគយ និង រដ្ឋាករ

នៃការិយាល័យស្រាវជ្រាវ និង បង្ក្រាបអំពើរត់ពន្ធ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- យោងសារាចរលេខ ០០១ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយ និង រដ្ឋាករ
- យោងអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការរំសាយ និង បង្កើតស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍ទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតស្នើសុំរបស់ទីចាត់ការគយ និង រដ្ឋាករលេខ ៦១៩ - ៩៦ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១.~ ត្រូវបានធ្វើការផ្លាស់ប្តូរមន្ត្រីរាជការគយ និង រដ្ឋាករ នៃ ការិយាល័យស្រាវជ្រាវ និង បង្ក្រាបអំពើរត់ពន្ធ ដូចមានរាយនាមខាងក្រោម ÷

១	លោក	**ហួត**	**ស៊ីថុល**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យឧដុង្គ
២	លោក	**ម៉ែន**	**សារ៉ាត**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៣	លោក	**សេង**	**សុខា**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៤	លោក	**នូ**	**សុផារ៉ា**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៥	លោក	**តាន់**	**គីមស៊ុន**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៦	លោក	**គង់**	**ប៊ុនថន**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៧	លោក	**សេង**	**ឡឿន**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៨	លោក	**សំ**	**ថុន**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
៩	លោក	**មាស**	**ប្រុសបំ**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១០	លោក	**ទឹម**	**គីមហួរ**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១១	លោក	**ឆូ**	**ជីវ**	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ

១២	លោក	ម៉ុល	សំណាង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៣	លោក	ខេព	ទិសិដ្ឋ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៤	លោក	សយ	សេងហ៊ា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៥	លោក	ឯក	បុរិន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៦	លោក	អៀង	ញឹម	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៧	លោក	គេច	សុគន្ធ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៨	លោក	ស	ឈុនហុង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ឧដុង្គ
១៩	លោក	សោម	អិល	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យព្រែកក្តាម
២០	លោក	ម៉ាត់	សាវុធ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២១	លោក	ផូ	សុខុម	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២២	លោក	ដួង	សុគំត្រ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៣	លោក	កៅ	ទិសុទ្ធ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៤	លោក	ម៉ុក	ហួត	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៥	លោក	គង់	សំបូរ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៦	លោក	ហុង	សារិន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៧	លោក	សំ	សាវ៉ាត	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ ព្រែកក្តាម
២៨	លោក	ចាន់	ឈាង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
២៩	លោក	ម៉ែន	សុផល	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣០	លោក	សារ	វ៉ាន់ចាន់	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣១	លោក	ថេង	សុគា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣២	លោក	ស៊ុន	សុខុម	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៣	លោក	ហង្ស	ពិសិដ្ឋ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៤	លោក	ស៊ុន	ឆាយ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៥	លោក	ម៉ៅ	សាវ៉ន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស

៣៦	លោក	យឹម	សំអន	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៧	លោក	អ៊ុំ	ខួន	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៨	លោក	ពុត	ឧត្តម	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៣៩	លោក	រស់	ពិសិដ្ឋ	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៤០	លោក	ពូ	សារ៉េត	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៤១	លោក	សោភ័	សទឿន	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៤២	លោក	ខាន់	រ៉េត	ភ្នាក់ងារស្នាក់ការត្រួតពិនិត្យកំពង់ផែក្នុងប្រទេស
៤៣	លោក	ច្រាក់	សុមេធ	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៤	លោក	ម៊ុន	ហ៊ន	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៥	លោក	សុខ	នួន	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៦	លោក	នៅ	ស៊ីថុ	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៧	លោក	ច្រាក់	ហេង	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៨	លោក	ហែម	សារ៉ែន	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៤៩	លោក	ប៊ិត	តិរុណា	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥០	លោក	ឡាយ	ម៉ុនសី	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥១	លោក	ជា	ហាក់	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥២	លោក	កង	ស៊ីថា	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥៣	លោក	ឈឹម	សុធា	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥៤	លោក	ជុំ	ប៉ៃលិន	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥៥	លោក	យឹម	សុផល	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ដើមមៀន
៥៦	លោក	ហុង	សង្វា	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ព្រះធាតុ
៥៧	លោក	យូ	ហេង	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ព្រះធាតុ
៥៨	លោក	ស៊ុម	សេន	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ព្រះធាតុ
៥៩	លោក	ហោ	វិជ្ជា	ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ ព្រះធាតុ

៦០	លោក	ម៉ុង	ដាវន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦១	លោក	ហ៊ុន	ឆាយ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦២	លោក	ហ៊ិន	សុវណ្ណ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៣	លោក	យឹម	ចាន់ថា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៤	លោក	សុន	ចន្ថា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៥	លោក	ឌុំ	ណារិទ្ធ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៦	លោក	កែវ	វ៉ាន្នី	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៧	លោក	យឹម	ណាវី	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៨	លោក	សឿ	ឌឿ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៦៩	លោក	ចក់	ចឿន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៧០	លោក	យី	ទខ្យ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៧១	លោក	យឹម	សុនិដ្ឋ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	ព្រះធាតុ
៧២	លោក	ស	សុផាត	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៣	លោក	ថេង	ម៉ុងហួន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៤	លោក	យ៉ែម	សេង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៥	លោក	នឹម	ផល្លី	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៦	លោក	កាយ	សុម	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៧	លោក	កែវ	វ៉ាន់ឌី	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៨	លោក	សំ	អឿន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៧៩	លោក	យ៉ិន	សាទុន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៨០	លោក	កែវ	វះ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៨១	លោក	ម៉ា	សាមឿន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៨២	លោក	ចាប	សាវ៉ាត	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	កំពង់ទួល
៨៣	លោក	កើត	សុធារ៉ា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង

៨៤	លោក	ឈាង	ហៃ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៨៥	លោក	គាន់	សារិន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៨៦	លោក	ពួន	ម៉េង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៨៧	លោក	សារឹម	ឧត្តី	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៨៨	លោក	ហ៊ាង	ឈាវ៉ាន់	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៨៩	លោក	អ៊ុង	សាមឹន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩០	លោក	ជុន	ហេង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩១	លោក	ឡឿម	រ៉ា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩២	លោក	គុជ	ហាច	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៣	លោក	ចែត	ឡុង	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៤	លោក	ផែន	តៀន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៥	លោក	ឃុត	ចន្ទ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៦	លោក	លី	តុលា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៧	លោក	សូ	ពេញ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៨	លោក	ពៅ	ចន្ថា	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
៩៩	លោក	កង	សុខន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០០	លោក	សឹម	សិត	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០១	លោក	យិន	រិន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០២	លោក	សុខ	គិរម្យ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០៣	លោក	ចាន់	ជីលុច	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០៤	លោក	គៀត	វណ្ណៈ	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០៥	លោក	ទឹម	ស៊ីវន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០៦	លោក	អ៊ុក	សឿន	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង
១០៧	លោក	ជឹម	សុផល	ភ្នាក់ងារ	ស្នាក់ការត្រួតពិនិត្យ	តាំងក្រសាំង

១០៨ លោក **សៅ ប្រុស** ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ តាំងក្រសាំង

១០៩ លោក **កៀម ម៉ុនណារ៉ឿន** ភ្នាក់ងារ ស្នាក់ការត្រួតពិនិត្យ តាំងក្រសាំង

ប្រការ ២.~ នាយកខុទ្ទកាល័យ ប្រធាន មន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ទីចាត់ការគយ និងរដ្ឋាករ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ២៥៦ សបប្រក.សហវ

ស្តីពីការបង្កើតក្រុមការងារអាសិរានអមទីចាត់ការគយ និង រដ្ឋាករ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១.~ បង្កើតក្រុមការងារមួយអោយទទួលបន្ទុកផ្នែកការងារអាស៊ាននៅទីចាត់ការគយ និង រដ្ឋាករ ដែលមានសមាសភាពដូចខាងក្រោម ÷

១_លោក	**ស្មៀង ឈុនឡី**	នាយករងទីចាត់ការគយ និង រដ្ឋាករ	ប្រធាន
២_លោក	**ជា ហាក់**	អនុប្រធានការិយាល័យវិវាទនិងច្បាប់	អនុប្រធាន
៣_លោក	**ម៉ែន សំអាត**	អនុប្រធានការិយាល័យត្រួតពិនិត្យ ទទួលបន្ទុកអចិន្ត្រៃយ៍	អនុប្រធាន
៤_លោក	**គេ សុមុនី**	ឋានៈអនុប្រធានស្នាក់ការគយនិងរដ្ឋាករ	សមាជិក
៥_លោក	**គីម ខួន**	ឋានៈអនុប្រធានស្នាក់ការគយនិងរដ្ឋាករ	សមាជិក
៦_លោក	**ដួង បូលីន**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក
៧_លោក	**ជា សារ៉ាត់**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក
៨_លោក	**ម៉ុក ឃួត**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក
៩_លោក	**វៀន សម្បត្តិ**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក
១០_លោក	**ហង្ស ច័ន្ទ**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក
១១_លោក	**ប្រាក់ សុម៉េត**	មន្ត្រីរាជការគយនិងរដ្ឋាករ	សមាជិក

ប្រការ ២.~ ក្រុមការងារអាស៊ានមានភារកិច្ចដូចតទៅ ÷

១–ស្រាវជ្រាវរៀបចំឯកសារពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ទីចាត់ការគយនិងរដ្ឋាករក្នុងការ ត្រៀមចូលជាសមាជិកអាស៊ាន ។

២–រៀបចំចងក្រងស្ថិតិទំនិញនាំចេញ សំរាប់ជាមូលដ្ឋានក្នុងការរៀបចំ Product List ដែលត្រូវបញ្ចូនក្នុង CEPT SCHEME នៃ AFTA ។

៣–សំរបសំរួលការងារជំនាញជាមួយនាយដ្ឋានអាស៊ាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអង្គភាព អាស៊ានអមក្រសួងពាក់ព័ន្ធដទៃទៀត ។

៤–តាមដានកិច្ចសហការជាមួយរដ្ឋបាលគយ នៃប្រទេសដែលជាសមាជិកដទៃទៀតរបស់សមាគមអាស៊ាន ។

ប្រការ៣.~ ក្រុមការងារអាស៊ានត្រូវបានទទួលភារកិច្ចដូចក្នុងប្រការ ២ បន្ថែមពីលើភារកិច្ចរបស់សមាជិកនៃក្រុមនេះដែលកំពុងមានបច្ចុប្បន្ន ។

ប្រការ ៤.~ ក្រុមការងារនេះមានសិទ្ធិអញ្ជើញមន្ត្រី និងភ្នាក់ងារគយក្នុងអង្គភាព , ការិយាល័យ , សាខាទាំងអស់ដែលមានការពាក់ព័ន្ធអោយចូលរួមធ្វើការងារ ការរៀបចំឯកសារការប្រជុំពិភាក្សាតាមការជាក់ស្តែង ។

ប្រការ ៥.~ នាយកខុទ្ទកាល័យ ប្រធាន មន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានក្រុមការងារអាស៊ាន នាយកទីចាត់ការគយ និង រដ្ឋាករ និងសាម៉ីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ២៥៧ ប្រក.សហវ.គរ

ស្តីពីការគ្រប់គ្រងលើទំនិញនាំចូល

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីពន្ធលើទំនិញនាំចេញនិង នាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញប្រកាសលេខ ១២៥ ប្រក.សហវ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ ១៩៩៤ ស្តីពីឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយ និងរដ្ឋាករ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១.- កំណត់រយៈពេលសិចតនៃទំនិញក្នុងឃ្លាំងឬទីលានបញ្ចេញទំនិញពីគយគឺមាន ÷

- ៣០ ថ្ងៃសំរាប់ឃ្លាំង និង ទីលានបញ្ចេញទំនិញពីគយដែលស្ថិតនៅព្រលានយន្តហោះ
- ៤៥ ថ្ងៃសំរាប់ឃ្លាំងនិងទីលានបញ្ចេញទំនិញពីគយដែលស្ថិតនៅកន្លែងក្រៅពីព្រលានយន្តហោះ ។ រយៈកាលនេះត្រូវគិតពីថ្ងៃចុះបញ្ជីកាប្រតិវេទន៍បំព្រួញ ។

ប្រការ ២.- ក្រោយពីថ្ងៃដែលបានកំណត់ដូចមានក្នុង ប្រការ១ ខាងលើ ទំនិញទាំងឡាយត្រូវដាក់ជា ស្វ័យប្រវត្តិក្នុងនិក្ខិត្តភ័ណ្ឌគយ (dépôt de douane) កាលបើទំនិញទាំងនោះពុំបានធ្វើប្រតិវេទន៍លំអិតនោះទេ ។ ក្នុងរយៈពេលដែលទំនិញត្រូវដាក់ក្នុងនិក្ខិត្ត-ភ័ណ្ឌគយ (dépôt de douane) នោះម្ចាស់ទំនិញត្រូវបង់កំរៃ (Redevance de dépôt) ០,១% លើថ្លៃទំនិញ (CIF) ក្នុងមួយថ្ងៃជូនរាជការគយនិងរដ្ឋាករ ។ ប្រាក់កំរៃទាំងនេះត្រូវកត់ត្រាចូលប្រតិវេទន៍លំអិត និង បង់ចូលថវិការដ្ឋតាមនាមវលីថវិកា (nomenclature budgétaire) ១៣.០១.០៣ ។ ទំនិញទាំងឡាយដែលត្រូវដឹកលំជានិក្ខិត្តភ័ណ្ឌគយនោះត្រូវកត់ត្រាចុះក្នុងបញ្ជីពិសេស ។

ប្រការ ៣.~ ទំនិញទាំងឡាយដែលគេពុំបានយកចេញក្នុងរយៈពេល ៣ ខែ គិតតាំងពីថ្ងៃការ ចូលក្នុង បញ្ជីនៃនិក្ខិត្តភ័ណ្ឌគយ ត្រូវដាក់លក់ឡាយឡុងជាសាធារណៈក្រោយមានការ អនុញ្ញាតពីតុលាការ ។

–ទំនិញទាំងឡាយដែលធាប់ខូច ឬ ទុកពុំបានយូរ អាចលក់បានមួយរំពេចដោយ មានការអនុញ្ញាតពីតុលាការ

–ទំនិញទាំងឡាយដែលមានតំលៃតិចជាង ១០០.០០០ រៀល ដែលគេពុំបានយក ចេញនៅពេលផុតរយៈវេលា ០៣ ខែ ដូចមានចង្អុលនៅក្នុងកថាខ័ណ្ឌទី១ ខាង លើត្រូវចាត់ ទុកជាគេបោះបង់ចោល ។ រាជការគយនិងរដ្ឋាករអាចដាក់លក់ឡាយ ឡុងបាន ឬ ធ្វើជា អំណោយដល់មន្ទីរពេទ្យ សង្គហដ្ឋាន (hospices) ឬគ្រឹះស្ថាន សប្បុរសធម៌ឯទៀតបាន ។

ប្រការ ៤.~ រាជការគយនិងរដ្ឋាករជាអ្នកចាត់ចែងតាមការលក់ដេញថ្លៃជាសាធារណៈ និងដល់អ្នក ហ៊ានអោយថ្លៃជាងគេក្រោយបំផុត ។ ទំនិញទាំងឡាយដែលដាក់លក់ត្រូវបានអោយ រួចពន្ធ និង អាករដែលភ្នាក់ងារនិងរដ្ឋាករត្រូវហូតយក ។ អ្នកដេញបានមានសិទ្ធិចាត់ ចែង ទំនិញនោះតាមគម្យស្ថាន (destination)ដែលច្បាប់និងបទបញ្ញាជាធរមានបាន អនុញ្ញាតអោយ ។

ប្រការ ៥.~ ផលពីការលក់ត្រូវយកទៅចាត់ចែងសងរហូតដល់គ្រប់ប្រាក់ជំពាក់តាមលំដាប់ អាទិភាពដូចតទៅ ÷

ក–កាត់សងសោហ៊ុយ និងចំណាយបន្ទាប់បន្សំគ្រប់ប្រភេទទាំងឡាយដែលភ្នាក់ងារ និងរដ្ឋាករបានចេញចាយក្នុងការតម្កល់និងការសំចតអោយនៅជានិក្ខិត្តភ័ណ្ឌ ព្រមទាំងការលក់ទំនិញទាំងនេះ ។

ខ–បង់ពន្ធនិងអាករដែលទំនិញទាំងឡាយត្រូវជាប់តាមគម្យដ្ឋាន ។

គ–ការកាត់សងប្រាក់កំរៃសោហ៊ុយដទៃទៀតដែលត្រូវចំណាយលើទំនិញ ។

–សំណល់ពីនេះត្រូវដាក់ទៅក្នុងបេឡានៃនិក្ខិត្តភ័ណ្ឌនិងបញ្ជីត្រូវទុក២ឆ្នាំដើម្បី រង់ចាំម្ចាស់ទំនិញ ឬ សិទ្ធិលាភទាំងឡាយ ។ ដល់ផុតរយៈវេលានេះ ត្រូវ បានជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។ ក៏ប៉ុន្តែកាលបើទំនិញដែលដាក់លក់

បានមិនលើសពី ១០០.០០០ រៀលទេ ប្រាក់សំណល់ត្រូវដាក់ជាចំណូល នៃថវិកាភូមិ ។

ប្រការ ៦.- ទំនិញទាំងឡាយដែលបាននាំចូលមុនថ្ងៃអនុវត្តប្រកាសនេះដែលកំពុងស្ថិតនៅក្នុងឃ្លាំងនោះក៏ត្រូវទទួលបន្ទុកអនុវត្តដូចប្រកាសនេះផងដែរ ។

ប្រការ ៧.- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៨.- ប្រកាសនេះអោយមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦ តទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ២៥៨ ប្រក.សហវ.គរ

ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើទំនិញនាំចេញ និង នាំចូលតាមកុងតឺន័រ « CONTAINER » ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យគ្រប់គ្រងដែសួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយ និង រដ្ឋាករ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញប្រកាសលេខ ១២៥ ប្រក.សហវ.គរ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣១៨ ប្រក.សហវ.គរ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០០៨ ប្រក.សហវ.គរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១.~ បណ្តាក្រុមហ៊ុន ឬ បុគ្គលដែលត្រូវយកកុងតឺន័រទំនិញមកធ្វើការត្រួតពិនិត្យ និង ឬ បង់ពន្ធនៅភ្នំពេញទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និង ត្រួតពិនិត្យដោយផ្ទាល់របស់ការិយាល័យគ្រប់គ្រងផែស្ងួត និង ឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ។

ប្រការ ២.~ ទំនិញនាំចូលតាមកុងតឺន័រ ដែលអាចយកមកធ្វើការត្រួតពិនិត្យ និង ឬ បង់ពន្ធនៅភ្នំពេញបាន ចាំបាច់ ត្រូវមានលិខិតអនុញ្ញាតពីទីចាត់ការគយនិងរដ្ឋាករ ជាមុន ។

ប្រការ ៣.~ ក្រោយពីបានលិខិតអនុញ្ញាតពីទីចាត់ការគយនិងរដ្ឋាករ ក្រុមហ៊ុន ឬ បុគ្គលដែលជាម្ចាស់ទំនិញ ឬ ម្ចាស់ផែស្ងួត ឬ ម្ចាស់ឃ្លាំងដែលគ្រប់គ្រងដោយ ការិយាល័យគ្រប់គ្រងផែស្ងួត និងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករក្រៅពីផែស្ងួត ត្រូវកក់ប្រាក់ ពន្ធនៅការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលាន បញ្ចេញទំនិញពីគយនិងរដ្ឋាករ ព្រមទាំងត្រូវបំពេញប្រតិវេទន៍ឆ្លងកាត់នៅទីស្នាក់ការ គយនិងរដ្ឋាករ នាមាត់ច្រកនាំ

ចូលទំនិញចំនួន ០៥ «ប្រាំ» ច្បាប់ ដោយបញ្ជាក់ ច្បាស់អំពីមុខទំនិញ លេខកុងតឺន័ និង លេខសៀល « SEAL » ។

ប្រការ ៤.- ការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយនិងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ត្រូវបញ្ជាក់អំពីមុខទំនិញ លេខកុងតឺន័ និង លេខសៀល ដែលបានទទួលយកមកធ្វើការគ្រប់គ្រងនៅលើ ប្រតិវេទន៍ឆ្លងកាត់ទាំងនោះ បន្ទាប់មកទើបអាចធ្វើការត្រួពិនិត្យ និង បង់ពន្ធបាន ក្រោយពេលដែលបណ្តា ក្រុមហ៊ុន ឬ បុគ្គលទាំងនោះបានបំពេញប្រតិវេទន៍គយលំអិតរួចហើយ ។

ប្រការ ៥.- បណ្តាក្រុមហ៊ុន ឬ បុគ្គល អាចបំពេញបែបបទនៅការិយាល័យគ្រប់គ្រងផែស្ងួតនិងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ បាន ចំពោះមុខទំនិញផ្ទុកក្នុងកុងតឺន័ ដើម្បីនាំចេញតាមបណ្តា ច្រកនាំចេញនានា ។

ប្រការ ៦.- ចំពោះទំនិញដែលត្រួតពិនិត្យឃើញមានការខុសពីប្រវេទន៍គយលំអិតនោះ បណ្តាក្រុមហ៊ុន ឬ បុគ្គល ឬ អ្នកតំណាង នឹងត្រូវទទួលទោសតាមច្បាប់ស្តីពីពន្ធលើ ទំនិញនាំចេញ - នាំចូល ។

ប្រការ ៧.- ទីចាត់ការគយនិងរដ្ឋាករ មានភារកិច្ចណែនាំលំអិតអំពីការប្រើប្រាស់ប្រតិវេទន៍ឆ្លងកាត់ ។

ប្រការ ៨.- ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩.- ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២៥៩ ប្រក.សហវ.ពដ

ស្តីពីការរៀបចំអោយមានផ្នែកកំណត់មូលដ្ឋាន

គិតពន្ធនិងផ្នែកប្រមូលពន្ធ នៅក្នុងសាខាពន្ធដារខេត្ត-ក្រុង

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាបាទសម្តេច **ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ ពិសេសមាត្រា ៣,៤,៧ ដល់ ១៨ មាត្រា ២២ មាត្រា ២៦ ដល់៣៣ មាត្រា ៦៨ដល់ មាត្រា ៨០ មាត្រា ៩៤ ដល់១០០ មាត្រា ១០២ ដល់១០៦ និងមាត្រា ១១១

– យោងតាមការចាំបាច់ នៃការងាររបស់ផ្នែកពន្ធដារ

សំរេច

ប្រការ ១ .–

អនុវត្តតាមគោលការណ៍ នៃការបែងចែកអាណាប័ក និងគណនេយ្យករ ចាប់ពីពេលនេះតទៅ នៅក្នុងសាខាពន្ធដារគ្រប់ខេត្ត–ក្រុង ត្រូវបានបំបែកការងារកំណត់មូលដ្ឋានគិតពន្ធអាករ ចេញពីការងារប្រមូលពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌសារពើពន្ធ ។

ប្រការ ២ .–

ប្រធានអង្គភាពពន្ធដារថ្នាក់ស្រុក–ខ័ណ្ឌ មានភារកិច្ចទទួលខុសត្រូវ :

–កំណត់មូលដ្ឋានគិតពន្ធអាករ គណនា និងត្រួតពិនិត្យពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

–បើកអោយមានសំណុំឯកសារមួយ សំរាប់អ្នកជាប់ពន្ធម្នាក់ៗ ដែលមានប្រាក់ចំណូលត្រូវជាប់ពន្ធអាករតាមរបបឆ្លើយប្រកាស ។

–បង្កើតបញ្ជីពន្ធប្រចាំខែ ឬ ប្រចាំត្រីមាស ចំពោះពន្ធអាករដែលមិនមែនជាកម្មវត្ថុនៃការឆ្លើយប្រកាសដែលត្រូវអមតាមដោយការបង់ប្រាក់ដោយម្ចាស់ការ ។

ប្រការ ៣ .–

ប្រគល់សិទ្ធិជូនប្រធានសាខាពន្ធដារខេត្ត–ក្រុង ជាអាណាប័កទទួលសិទ្ធិប្រទានក្នុងការអនុវត្តមតិបញ្ជីពន្ធ ។

បញ្ជីពន្ធត្រូវបញ្ជូនអោយគណនេយ្យករពន្ធដារ ដែលមានសមត្ថកិច្ចសំរាប់ធ្វើជាការទទួលបន្ទុកទារប្រមូល ។

ការទទួលបន្ទុកទារប្រមូល ត្រូវប្រព្រឹត្តទៅដោយការបង្កើតដីកាចំណូលឯ[illegible]ត ។

ប្រការ ៤ .–

នៅសាខាពន្ធដាខេត្ត–ក្រុងនីមួយៗ ត្រូវបានបង្កើតអោយមានប៉ុស្តិ៍គណនេយ្យនានា សំរាប់ប្រមូលប្រាក់ពន្ធអាករ និងប្រាក់ពិន័យពីទោសទ័ណ្ឌ ដែលទាក់ទងនឹងពន្ធអាករទាំងឡាយ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សាខាពន្ធដារខេត្ត–ក្រុង ។

ប្រការ ៥ .–

ការដឹកនាំការងាររបស់ប៉ុស្តិ៍គណនេយ្យពន្ធដារនីមួយៗ ត្រូវបានប្រគល់ជូនតែគណនេយ្យករមួយរូបប៉ុណ្ណោះ ដែលជាអ្នកមានលក្ខណៈសម្បត្តិជាគណនេយ្យករសាធារណៈ ។

គណនេយ្យករពន្ធដារ ដែលបំពេញមុខងាររបស់ខ្លួននៅទីចាត់ការ នៃសាខាពន្ធដារខេត្ត–ក្រុង មានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ ។

គណនេយ្យករពន្ធដារ ដែលបំពេញមុខងាររបស់ខ្លួននៅអង្គភាពពន្ធថ្នាក់ស្រុក–ខ័ណ្ឌ មានលក្ខណៈសម្បត្តិជាគណនេយ្យកររង ។

ប្រការ ៦ .–

ការទទួលខុសត្រូវ និងការតព្វកិច្ចរបស់គណនេយ្យករពន្ធដារ គឺជាការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់គណនេយ្យករសាធារណៈ ដូចបានចង្អុលបញ្ជាក់ក្នុងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។

ប្រការ ៧ .–

គណនាគកររងត្រូវទទួលបន្ទុកធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធដែលបានគណនេយ្យនាដោយផ្នែកកំណត់មូលដ្ឋានគិតពន្ធ នៃអង្គភាពពន្ធដារថ្នាក់ស្រុក–ខ័ណ្ឌ ។

គណនេយ្យករដើមខ្សែត្រូវទទួលបន្ទុកធ្វើបេឡានិច្ច័យ និងធ្វើគណនេយ្យកម្មប្រាក់ពន្ធដែលបានគណនាដោយផ្នែកកំណត់ពន្ធនៃទីចាត់ការរបស់សាខាពន្ធដារខេត្ត–ក្រុង ។

គណនេយ្យករដើមខ្សែក៏មានសមត្ថកិច្ចផងដែរ ក្នុងការធ្វើកិច្ចកាទារប្រមូលតាមរបៀបបង្ខំនូវប្រាក់ពន្ធអាករ ឬ ប្រាក់ពិន័យពីទោសទ័ណ្ឌនានា ដែលត្រូវបានគណនាដោយផ្នែកកំណត់ពន្ធណាមួយ ដែលស្ថិតក្នុងដែនដីនៃដែនអំណាចរបស់សាខាពន្ធដារខេត្ត–ក្រុង ហើយដែលមិនបានបង់ក្នុងរយៈពេលដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

គណនេយ្យករដើមខ្សែ ប្រមូលផ្តុំប្រតិបត្តិការដែលបានធ្វើគណនេយ្យកម្មដោយគណនេយ្យកររង និង បង្កើតស្ថិតិ នៃការប្រមូលពន្ធដោយសាខាពន្ធដារខេត្ត–ក្រុង ។

គណនេយ្យកររង និង គណនេយ្យករដើមខ្សែ ត្រូវចាត់ចែងក្រោមការទទួលខុសត្រូវរបស់ខ្លួន នូវការផ្ទេរប្រាក់ដែលខ្លួនបានធ្វើបេឡានិច្ច័យបង់ចូលរតនាគារជាតិ ។

ប្រការ ៨ .–

គណនេយ្យកររងម្នាក់ៗ ត្រូវស្ថិតនៅក្រោមអំណាចផ្ទាល់ តាមឋានានុក្រមរបស់គណនេយ្យករដើមខ្សែ ។

គណនេយ្យករដើមខ្សែ ត្រូវស្ថិតនៅក្រោមអំណាចផ្ទាល់ តាមឋានានុក្រមរបស់ប្រធានសាខាពន្ធដារខេត្ត–ក្រុង ។

ប្រការ ៩ .–

ការងារដែលជាបន្ទុករបស់អាណាប័កទទួលសិទ្ធិប្រទាន ព្រមទាំងការងាររបស់គណនេយ្យករដើមខ្សែ និងគណនេយ្យកររង ហើយនិងទំនាក់ទំនងការងាររវាងផ្នែកទាំងនេះ ត្រូវបានកំណត់បញ្ជាក់ដោយកំណត់ណែនាំមួយដោយឡែក ។

ប្រការ ១០ .–

នីតិវិធី និង បរិបថ នៃការផ្ទេរប្រាក់ចំណូលសារពើពន្ធបង់ចូលរតនាគារជាតិ ត្រូវបានណែនាំដោយសារាចររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១១ .–

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ២៦២ ឧបប្រក.សហវ

ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការជាគណនេយ្យករគយនិង រដ្ឋាករ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញលិខិតស្នើសុំរបស់ទីចាត់ការគយនិងរដ្ឋាករលេខ ៦៣២/៩៦ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៦

សម្រេច

ប្រការ ១.- ត្រូវបានធ្វើការផ្ទេរភារកិច្ចគណនេយ្យករ ចំនួន ១៦ នាក់ ដូចមានរាយនាមខាងក្រោម ÷

១-លោក **ខេង ខុន** ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករផែក្រុងព្រះសីហនុទៅជាគណនេយ្យករសាខាគយនិងរដ្ឋាករ ខេត្តស្វាយរៀង

២-លោក **ឯម ឧសារិទ្ធ** ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករផែក្រុងព្រះសីហនុ ទៅជាគណនេយ្យករសាខាគយ និងរដ្ឋាករខេត្តតាកែវ

៣-លោក **ប៉ុល សំណាន** ផ្ទេរពីគណនេយ្យករ ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ ទៅជាគណនេយ្យករសាខាគយ និង រដ្ឋាករខេត្តកណ្តាល

៤-លោក **តៅ សានឃួរ** ផ្ទេរពីគណនេយ្យករ ការិយាល័យគយនិងរដ្ឋាករផែភ្នំពេញទៅជា គណនេយ្យករសាខាគយនិងរដ្ឋាករក្រុងព្រះសីហនុ

៥-លោក **ស៊ េ ប៉ាន់យ៉ាពង្ស** ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករទឹកថ្លា ទៅជាគណនេយ្យករសាខាគយនិងរដ្ឋាករខេត្តកោះកុង

៦-លោក **ហួត ស៊ីផុល** ផ្ទេរពីគណនេយ្យករ ការិយាល័យស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធទៅជាគណនេយ្យករសាខាគយ និងរដ្ឋាករ ខេត្តបាត់ដំបង

៧-លោក **អ៊ុង អេង** ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករប៉ោយប៉ែតទៅជាគណនេយ្យករសាខាគយ និង រដ្ឋាករខេត្តបន្ទាយមានជ័យ

៨-លោក **ឧង សុគន្ធនារា** ផ្ទេរពីគណនេយ្យករ ការិយាល័យគយនិងរដ្ឋាករផែភ្នំពេញទៅជា គណនេយ្យករការិយាល័យ គយនិងរដ្ឋាករផែស្វួត

៩-លោក **នួន ចាន់ធុល** ផ្ទេរពីគណនេយ្យករ សាខាគយនិងរដ្ឋាករខេត្តកោះកុងទៅជាការិយាល័យគយនិងរដ្ឋាករ ផែស្វួត

១០-លោក **អ៊ុច សារអាន** ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករភ្នំដិនទៅជាគណនេយ្យករការិយាល័យគយនិងរដ្ឋា.

ផែភ្នំពេញ

១១-លោកតែ ប៊ុនឆី ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករក្អម សំណរទៅជាគណនេយ្យករការិយាល័យគយនិងរដ្ឋាករផែភ្នំពេញ

១២-លោកស្រី រស់ ឆទី ផ្ទេរពីគណនេយ្យករ ស្នាក់ការគយនិងរដ្ឋាករក្អម សំណរទៅជាគណនេយ្យករការិយាល័យគយនិងរដ្ឋាករ ពោធិចិនតុង

១៣-លោកស្រី សែម សុផល្លី ផ្ទេរពីគណនេយ្យករ ការិយាល័យគយនិងរដ្ឋាករផែភ្នំពេញ ទៅជាគណនេយ្យករការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ

១៤-លោក លីម សារ៉េត ផ្ទេរពីគណនេយ្យករ សាខាគយនិងរដ្ឋាករក្រុងព្រះសីហនុ ទៅជាគណនេយ្យករការិយាល័យរដ្ឋាករ

១៥-លោក មេ ធីរៈ ផ្ទេរពីគណនេយ្យ ស្នាក់ការគយនិងរដ្ឋាករកំពង់ត្រសាំងទៅជាគណនេយ្យករស្នាក់ការគយនិងរដ្ឋាករផែក្រុងព្រះសីហនុ

១៦-លោក ម៉ម ម៉ឿន ផ្ទេរពីគណនេយ្យករស្នាក់ការគយនិងរដ្ឋាករក្អម សំណរទៅជាគណនេយ្យករស្នាក់ការគយ និង រដ្ឋាករផែក្រុងព្រះសីហនុ

ប្រការ ២.- នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ទីចាត់ការគយ និងរដ្ឋាករ និងសាមីខ្លួនត្រូវទទួលអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៦ ប្រក.សហវ.រវ

ស្តីពីការប្រគល់ភារកិច្ចការងារជូនមន្ត្រីរាជការរតនាគារ

ក្រុងព្រះសីហនុ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញប្រកាសលេខៈ ២១៧ ប្រក-សហវ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្ទាកភារកិច្ចការងារមន្ត្រីរាជការ ។

សំរេច

ប្រការ ១ : ត្រូវបានប្រគល់ភារកិច្ចការងារជាបណ្តោះអាសន្ន ចំពោះមន្ត្រីរាជការរតនាគារក្រុងព្រះសីហនុ ដូចខាងក្រោម ÷

១-លោក **ហ៊ូ ហ៊ាន** អនុប្រធានទី១ រតនាគារក្រុងព្រះសីហនុ ជាប្រធានស្តីទីទទួលបន្ទុកផ្ទាល់ផ្នែករដ្ឋបាល-បុគ្គលិក និង ទទួលបន្ទុកដឹកនាំការងាររួមជំនួសលោកប្រធាន រតនាគារក្រុងព្រះ សីហនុដែលត្រូវផ្អាកភារកិច្ចការងារបណ្តោះអាសន្ន ។

២-លោក **យិន ពិសាយ** អនុប្រធានរតនាគារក្រុងព្រះសីហនុ អោយទទួលបន្ទុកផ្នែកគណនេយ្យ និង បេឡាព្រមទាំងទទួលៈបន្ទុកដឹកនាំការងាររួម នៅពេលអវត្តមានលោកប្រធានស្តីទី ។

៣–លោកស្រី **ឧន សុយ៉ុន** អនុប្រធានផ្នែកគណនេយ្យ អោយទទួលបន្ទុកដឹកនាំការងាររួមក្នុងផ្នែកគណនេយ្យ ។

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានរតនាគារជាតិ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១២ សហវ.ប្រក,ប

ស្តីពីការបង្កើតនាយកដ្ឋានអាស៊ាន

មណ្ឌលៈអាសន្ន ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស- រកម ០១៩៦–១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល

- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបាត់តាំង និង ការប្រព្រឹត្តិទៅនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (Internal Coordination Network)
- បានឃើញ ការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតនាយកដ្ឋានអាស៊ាន បណ្តោះអាសន្ន ក្នុងការរង់ចាំការសំរេច ដោយអនុក្រឹត្យ របស់ រាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ២ : នាយកដ្ឋានអាស៊ាន មានតួនាទី និង ភារកិច្ច អនុវត្តការងារសំខាន់ៗ ដែលពាក់ព័ន្ធការងារអាស៊ានដូចមានចែងក្នុងអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមិថុនាឆ្នាំ១៩៩៦ របស់ រាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធចំណុះក្រសួង ត្រូវមានភារកិច្ចទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៤ សហវ.ប្រក.ប

ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម.០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-លោក **ទឹម៉ន សេស** ពីអនុប្រធាននាយកដ្ឋានថវិការដ្ឋ មកជាអនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ

២-លោក **សាន ផាន់នី** ពីអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស មកជាអនុប្រធាននាយកដ្ឋានគ្រប់គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋាន «គ្រប់គ្រងទ្រព្យរដ្ឋ»

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានថវិការដ្ឋ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈប្រធាន នាយកដ្ឋានគ្រប់ គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋាន «គ្រប់គ្រងទ្រព្យរដ្ឋ» និង អង្គភាពពាក់ព័ន្ធចំណុះក្រសួង ព្រមទាំងសាមីខ្លួន ដូចក្នុងប្រការ១ ខាងលើត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១១៥ សហវ.ប្រក.ប

ស្តីពីការតែងតាំងមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស.រកម.០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១– លោក **ខាំ ឧុធណា** ជាអនុប្រធានអង្គភាពសេដ្ឋកិច្ច ទទួលបន្ទុកខាងវិភាគសេដ្ឋកិច្ច «ថ្នាក់ស្មើនឹងអនុប្រធាននាយកដ្ឋាន»

២–លោក **គីម ផល្លា** ជាអនុប្រធានអង្គភាពសេដ្ឋកិច្ច ទទួលបន្ទុកខាងស្ថិតិ «ថ្នាក់ស្មើនឹងអនុប្រធាននាយកដ្ឋាន»

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំង សាមីខ្លួនដូចក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

គាត ឈន់

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៤៦៤ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គង់ សុគន្ធ** ម្ចាស់សិប្បកម្មផលិតសំភារៈអាលុយមីញ៉ូម សញ្ញា «ផ្កាយបី» ដែលមានទីតាំងផ្ទះលេខ ១ ផ្លូវលេខ ៣៣៩ សង្កាត់ បឹងកក់ទី ១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ផ្ទេរសិទ្ធិគ្រប់គ្រងលើសិប្បកម្មនេះជូនលោក **ទិញ ពៅ** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៤៦០០ ភ.ព ចុះថ្ងៃទី ១៣-១១-១៩៩៦ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១ ផ្លូវលេខ ៣៣៩ សង្កាត់ បឹងព្រលិត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ទទួលស្គាល់លោក **ទិញ ពៅ** ជាម្ចាស់សិប្បកម្មផលិតសំភារៈអាលុយមីញ៉ូម សញ្ញា «ផ្កាយបី» ដែល មានទីតាំងផ្ទះលេខ ១ ផ្លូវលេខ ៣៣៧ សង្កាត់ បឹងកក់ទី១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ។

ប្រការ ៣ : លោក **ទិញ ពៅ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខា លើប្រកាសនេះតទៅ ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៦៥ ឧក. ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ហែម ម៉ីណ្ណា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៩៧៣៥០ ព.ស ចុះថ្ងៃទី ១៧-៣-៩០ អាស័យដ្ឋាន បច្ចុប្បន្នក្រុមទី ៣ ភូមិវាល ឃុំ វាល ស្រុក កណ្ដៀងខេត្ត ពោធិសាត់ បើកដំណើរ

ការរោងជាងផលិតគ្រឿងសង្ហារឹម នៅក្នុង ទីតាំង ក្រុមទី ១៧ ភូមិពាមព្រែក ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិសាត់ ។

ប្រការ ២ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់រោងជាងត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិស្ថាន ធានាគុណភាពផលិតផល ព្រមទាំងត្រូវគោរពពេញច្បាប់ និង បទបញ្ញត្តិ ដែលមានជាធរមាន។

ប្រការ ៣ : រោងជាងនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសម្ភារៈ តុ ទូ គ្រែ ទ្វារ និង បង្អួច ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតផលកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ដែលសាមីរោងជាងត្រូវរ៉ាប់រងដោះស្រាយដោយខ្លួនឯង ។

ប្រការ ៤ : ម្ចាស់រោងជាងត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់រោងជាងផ្ញើជូនមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តពោធិសាត់ ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់រោងជាងត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៦៦ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **គឿង អឿនឡូ** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជាកាន់អត្តសញ្ញាណ ប័ណ្ណលេខ ២០២៤៧៨ ភ.ព ចុះថ្ងៃទី ១៦-៦-៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦០ អឺ០ ផ្លូវលេខ ២២២ ក្រុមទី ១៨ សង្កាត់ បឹងរាំងខ័ណ្ឌ ដូនពេញរាជធានីភ្នំពេញបន្តដំណើការសិប្បកម្ម ផលិតកាហ្វេ តែ «គៀងស៊ុនហ៊្វួត» នៅក្នុងទីតាំងដូច អាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គឿង អឿនឡូ** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលការហ្វេ សញ្ញា «ក្ងោកពីរ»តែ សញ្ញា«ក្ងោកពីរ»និង តែ សញ្ញា«កង្កែបពីរ» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ ផលិតផល គ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៤៦៧ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង លី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥២៤២២ ភ.ព ចុះថ្ងៃទី ២៥-០៧-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៧១ ផ្លូវគ្រសក់ផ្អែម សង្កាត់ បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើការ សិប្បកម្មផលិត ទ្វារ បង្អួចអាលុយមីញ៉ូម នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៦៨ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឃឹម ទិចិត្រា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៦៩៨៦ ភ.ព ចុះថ្ងៃទី ០៥-៤-១៩៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៥ អឺ ១ ផ្លូវជាតិលេខ ១ ភូមិ កណ្តាល សង្កាត់ ច្បារអំពៅទី២ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិតសំឡីអនាម័យ និង ក្រដាសអនាម័យ «សុខភាព»នៅក្នុងទីតាំងដីឡូត៍លេខ ០៦ ផ្លូវលេខ ៣៦១ ភូមិ ម៉ាក់ស្លឿ សង្កាត់ ច្បារអំពៅទី ២ ខណ្ឌមានជ័យ រាជធានី ភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស

ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៦៩ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឃិន ទិចិត្រា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៩៦៩៨៦ ភ.ព ចុះថ្ងៃទី ០៥–៤–១៩៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៥ អឺ១ ផ្លូវជាតិ លេខ ១ ភូមិកណ្ដាល សង្កាត់ ច្បារអំពៅទី ២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូច ផលិតបាន ឆ្នាំង អំពីអាលុយមីញ៉ូមទន់ នៅក្នុងទីតាំង ដីឡូត៍លេខ ០៦ ផ្លូវ លេខ ៣៦១ ភូមិម៉ាក់ភឿ សង្កាត់ ច្បារអំពៅទី ២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : អ្នកស្រី **ឃិន ទិចិត្រា** ត្រូវរៀបចំឧស្សាហកម្មតូចរបស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេលបីខែ យ៉ាងយូរ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសរយៈពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : អ្នកស្រី **ឃុន ទិចិត្រា** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល បានឆ្នាំង សញ្ញា«អង្គរ» អំពីអាលុយមីញ៉ូមទន់ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវផ្ញើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយ មានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧០ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ចាយ ស៊ាងអ៊ី** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៤៧៧៣៨ ភ.ព ចុះថ្ងៃទី ០២–០២–៨៥ អាស[illegible]ដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៤៣ អឺ០ ផ្លូវលេខ ១១០ សង្កាត់វត្តភ្នំ ខ័ណ្ឌ ដូនពេញ

រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិត ស្រាកែច្នៃសញ្ញា«ដើមក្រវ៉ាញ»នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ចាយ ស៊ាវអ៊ី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលស្រាកែច្នៃសញ្ញា «ដើមក្រវ៉ាញ» និង«ភ្នំក្រវ៉ាញ»ស្របតាមគំរូ សញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧១ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឈូក និមឆាន់** ជនជាតិ ខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤១៦៥៥ ភ.ព ចុះថ្ងៃទី ២០–៨–៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២២៨ អឺ0 វិថី ខេមរភូមិន្ទ សង្កាត់ ផ្សារថ្មីទី ៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្តូរទីតាំងពីផ្ទះលេខ ២២៨ អឺ0 ផ្លូវខេមរភូមិន្ទ សង្កាត់ ផ្សារថ្មី ទី ៣ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទៅកាន់ទីតាំងថ្មីផ្លូវរោងចក្រកែវ ភូមិ ថ្មី សង្កាត់ ដង្កោ ខ័ណ្ឌ ដង្កោ រាជធានី ភ្នំពេញ និង ប្តូរឈ្មោះពី សិប្បកម្មកែច្នៃ ស្រាសញ្ញា «ប្រទាលក្រុងសិរិទ្ធ»មកជាសហគ្រាសជំបងដែកផលិតស្រាកែច្នៃ សញ្ញា «ប្រទាលក្រុងសិរិទ្ធ»វិញ ។

ប្រការ ២ : ទទួលស្គាល់សហគ្រាសជំបងដែក ផលិតស្រាកែច្នៃ សញ្ញា «ប្រទាលក្រុងសិរិទ្ធ» ដែលមានទី តាំងផ្លូវរោងចក្រកែវភូមិ ថ្មី សង្កាត់ ដង្កោ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ចាប់តាំងពីថ្ងៃដែល បានចុះហត្ថលេខាលើប្រកាសនេះ តទៅ ។

ប្រការ ៣ : លោក **ឈូក និមឆាន់** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្ម និងផលិតបន្ថែមនូវ មុខផលិតផលស្រាកែច្នៃចំនួន ៥ មុខ គឺ ស្រាសុខភាពល្អ «វរបរិមានឯករាជ្យ»ស្រា «ពងអណ្តើក»ស្រា«ពងមាន់»ស្រា «ចេកមាស»និងស្រា«ហង្សមាស» លើមុខផលិតផលចាស់ចំនួន ៤ មុខ គឺស្រា«អង្គុញ–គីង្គក់»ស្រា«ក្របីឡើងក» ស្រា

«បាយ័នវិស្គី» និងស្រា«ដំណើបខ្មៅ កម្ពុជា» ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់សដល់សុខភាពប្រជារាស្ត្រឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧២ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឡា ឡេង** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៦៨២៨៥ ភ.ព ចុះថ្ងៃទី ១៥–៥–៩៣ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ២៨០ ផ្លូវ ឧកញ៉ាទេពផន សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការសិប្បកម្ម ផលិតទឹកស៊ីរ៉ូសញ្ញា «រូបផ្លែម្នាស់» នៅក្នុងទីតាំង ផ្ទះលេខ ៥ ផ្លូវលេខ ៣៣៦ ក្រុមទី៤៨ សង្កាត់ វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ឡា ឡេង** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល ទឹកស៊ីរ៉ូ សញ្ញា «រូបផ្លែម្នាស់» ស្រប តាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧៣ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឃឹម សុផល** ជនជាតិ ខ្មែរ សញ្ញាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៥៥២៤៨ ក.ណ ចុះថ្ងៃទី ២៥-១១-៩០ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ៥ ឃុំសំពៅពូន ស្រុកកោះធំ ខេត្ត កណ្តាល បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទី តាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ឃឹម សុផល** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧៤ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **អៀវ សុខហាំង** ជនជាតិ ខ្មែរ សញ្ញាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១៥២៤៨១ក.ណ ចុះថ្ងៃទី ១៤-១២-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់ចម្លង ឃុំកំពង់ចំលង ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល បន្តដំណើការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **អៀវ សុខហាំង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិ

ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧៥ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **សោម សុវណ្ណ** ម្ចាស់ឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា «ត្បូង»និង ទឹកកកអនាម័យ ផ្ទេរសិទ្ធិគ្រប់គ្រងលើឧស្សាហកម្មតូចនេះជូនអ្នកស្រី **សុខ ធាន** វិញ ។

ប្រការ ២ : ទទួលស្គាល់អ្នកស្រី **សុខ ធាន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៥៣៧ ភ.ព ចុះថ្ងៃទី ១៤-១០-៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ បន្ទាយចាស់ ឃុំស្លក្រាម ស្រុក សៀមរាប ខេត្ត សៀមរាប ជាម្ចាស់ឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធសញ្ញា«ត្បូង»និងទឹកកកអនាម័យ ដែលមានទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ៣ : អ្នកស្រី **សុខ ធាន** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្មលើមុខផលិតផល ទឹកបរិសុទ្ធសញ្ញា«ត្បូង»និងទឹកកកអនាម័យ ស្របតាមគំរូ សញ្ញាសំគាល់ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ ការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មាន គុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧៦ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឡុង ម៉ា** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២១៦៧២ ប.ជ ចុះថ្ងៃ ០៣-៨-៨៩ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី៤ ភូមិ

ថ្មល់បត់ ឃុំ រហាត់ទឹក ស្រុក មង្គលបូរី ខេត្ត បន្ទាយមានជ័យ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : អ្នកស្រី **ឡុង ខ៊ា** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដែលបានកំណត់ ក្នុង ប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤៧៧ ឧក.ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន អ៊ីវិន អ៊ិនធឺណាស់ស្យូងណាស់ ធូប៊ែកខូ ខូអិលធីឌី (EVAN'S INTERNATIONAL TOBACCO CO,LTD) តំណាងដោយលោក HUYNH HOA BANG សញ្ជាតិអាមេរិកាំង អាយុ ៤៩ ឆ្នាំ ភេទ ប្រុស អាស័យដ្ឋាន 2450 DALY STREET , LOS ANGELES , CA 90031 USA បង្កើត«រោងចក្រផលិតបារីនាំចេញ» ដែលមានឈ្មោះ «រោង ចក្រផលិតបារី»អ៊ីវិន អ៊ិធឺណាស់ស្យូងណាស់ធូប៊ែកខូ» មានទីតាំងស្ថិតនៅ ភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់និងរៀបចំគ្រឿងចក្រត្រូវធ្វើទៅតាមប្លង់ ដែលបានដាក់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ៩ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាព ផលិតផល ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល«បារី» ទៅតាមគំរូ និង ផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ និង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ញ៉ូ សុធីរ:

* * *

៣_ឯកសារនៃក្រសួងមហាផ្ទៃ

សារាចរ

ភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៨៦

សារាចរលេខ : ០០២ ស.រ.

អនុវត្តច្បាប់ ស្តីពីការបង្ក្រាបល្បែងស៊ីសង

ដើម្បីធានាការអនុវត្តន៍ច្បាប់ ស្តីពីការបង្ក្រាបល្បែងបស៊ីសងដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម.០១៨៦.២៨ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៦ អោយមាន ប្រសិទ្ធភាពក្រសួងសូមណែនាំនូវវិធានការដូចខាងក្រោមនេះ ÷

១–អភិបាលខេត្ត ក្រុង និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និង ក្រុងកែប ក្នុងតួនាទីជាប្រធានគណ:បញ្ជាការឯកភាពខេត្ត ក្រុង ត្រូវមានវិធានការម៉ឺងម៉ាត់ ដល់មន្ត្រីរាជការ ស៊ីវិលនគរបាលជាតិ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ ដែលស្ថិតនៅក្រោមឱវាទ និង កំពុងរស់នៅ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនអោយអនុវត្តច្បាប់ ស្តីពីការបង្ក្រាបល្បែងស៊ីសងដោយហាមមិនអោយ មន្ត្រីរាជការស៊ីវិលនគរបាលជាតិ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង ប្រជាពលរដ្ឋ ទាំងអស់លេងល្បែងស៊ីសង ឬការពារ ឬបើកបនល្បែងស៊ីសងជាដាច់ខាត ។

អ្នកប្រព្រឹត្តបទល្មើស ត្រូវចាប់បញ្ជូនខ្លួនទៅតុលាការ ។

២–អំពីសមត្ថកិច្ចក្នុងការបង្ក្រាបល្បែងស៊ីសង :

ការបង្ក្រាបល្បែងស៊ីសងជាសមត្ថកិច្ចរបស់មន្ត្រី ដូចខាងក្រោម ÷

–អភិបាល អភិបាលរងខេត្ត ក្រុង ស្រុក ខ័ណ្ឌ ។

–អគ្គនាយក អគ្គនាយករងនគរបាលជាតិ ។

–ប្រធាន អនុប្រធាន នាយកដ្ឋានកណ្ដាល នគរបាលយុត្តិធម៌ ។

–ប្រធាន អនុប្រធាន នាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ ។

–ស្នងការ ស្នងការរង ។

–ប្រធានការិយាល័យនគរបាលព្រហ្មទ័ណ្ឌ គីរីតស្រាល ។

–អធិការ អធិការរង ។

–ប្រធានប៉ុស្តិ៍ នគរបាលរដ្ឋបាល ។

ដោយឡែកការរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣–អំពីនីតិវិធី នៃការរឹបអូសប្រាក់ក្នុងវង់ល្បែង និង វត្ថុតាង :

ក្នុងករណីណាក៏ដោយ ប្រាក់ដាក់ក្នុងវង់ល្បែង ប្រាក់មាននៅនឹងខ្លួនអ្នកចាត់ចែងល្បែង នៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការី និង នៅនឹងខ្លួនអ្នកលេងល្បែង ត្រូវមន្ត្រីមានសមត្ថកិច្ច ដូចបានរៀបរាប់ខាងលើចាប់រឹបអូស ហើយធ្វើកំណត់ហេតុអោយបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

ចំណែកវត្ថុតាងសំរាប់បំរើអោយការលេងល្បែងនោះក៏ត្រូវរឹបអូសដូចប្រាក់ដែរ ។

ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ឧបករណ៍ល្បែងស៊ីសងគ្រប់ ប្រភេទ ដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្ដន្ទាទោសតាមមាត្រា ៨ នៃច្បាប់ ស្ដីពីការបង្ក្រាបល្បែងស៊ីសង ។ ឧបករណ៍នៃវត្ថុតាងនេះ ក៏មន្ត្រីមានសមត្ថកិច្ច ត្រូវរឹបអូសដែរ ។

ប្រាក់ និង វត្ថុតាងទាំងអស់ដែលរឹបអូសបានដូចខាងលើ មន្ត្រីមានសមត្ថកិច្ច ត្រូវតែបញ្ជូនជាមួយនឹងសំណុំរឿងទៅតុលាការ ដើម្បីសំរេចរឹបអូស ឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សំរាប់មន្ត្រីមានសមត្ថកិច្ច អង្គភាព និង ជនដែលបានចូលរួមកិច្ចប្រតិបត្តិការនេះ និង មានកំណត់ដោយឡែកក្នុងអនុក្រឹត្យ ។

៤–អំពីប្រភេទ នៃល្បែងស៊ីសងដែលត្រូវបង្ក្រាប :

–ល្បែងបៀគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងឡូតូ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ឆ្នោតគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ រួមទាំងកន្ទុយលេខផង

-ឆ្នោតវត្ថុគ្រប់ប្រភេទ

-ល្បែងអាប៉ោង ធ្វ ឡុកឡាក់ យុតី និង ខ្លាឃ្លោក ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់ ។

-ល្បែងជល់សត្វ ឬ ប្រណាំងសត្វគ្រប់ប្រភេទស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាចប្រាក់ ។

-ល្បែងទឹកភ្លៀងគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងរូលឡែត គ្រប់រូបភាព ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងវីដេអូហ្គេមគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ព្រមទាំងល្បែងស៊ីសងទាំងឡាយដទៃទៀត ។

ល្បែងស៊ីសងទាំងអស់ខាងលើនេះអាចលេងបាន បើមានការអនុញ្ញាតច្បាប់ពីរាជរដ្ឋាភិបាល ក្នុងករណីគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល មន្ត្រីមានសមត្ថកិច្ចបង្ក្រាបល្បែងស៊ីសងដូចមានចែង ក្នុងចំណុចទី ២ នៃសារាចរនេះ ត្រូវចាត់វិធានការបង្ក្រាបជាបន្ទាន់ ។

ក្រសួងប្រគល់ភារកិច្ចអោយអគ្គនាយកនគរបាលជាតិ ធ្វើជាសេនាធិការដើម្បីចង្អុលណែនាំ លើកទិស និង ដឹកនាំអនុវត្តការងារនេះ ។

សារាចរនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និង ត្រា

ស ខេង យូ ហុកគ្រី

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២២៨.៩៦ ពម.បសន.ប្រក

អនុញ្ញាតជូនអ្នកស្រី អ៊ុន សុផល បើកអាជីវកម្ម

រោងចក្រឈ្មោះ «សុផល»

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងលិខិតជូនដំណឹងរបស់ក្រសួងពតិមានលេខ ១២២៤.៩៤ ពម ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ពឈ្មោះ «សុផល »របស់អ្នកស្រី **អ៊ុត —សុផល** ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនអ្នកស្រី **អ៊ុតសុផល** អាស័យដ្ឋានផ្ទះលេខ ១២៧ E.o ផ្លូវលេខ ១៣៦ សង្កាត់ផ្សារកណ្តាល II ខ័ណ្ឌដូនពេញ , រាជធានីភ្នំពេញ បើកអាជីវកម្ម រោងពុម្ព ដែលមានឈ្មោះ «សុផល »ទីតាំងស្ថិតនៅលំនៅស្ថានដូចខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របទៅនឹងទំនៀម ទំលាប់ សន្តិសុខ សណ្តាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាម ច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និង សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ២២៩.៩៦ ពម.បសឧ.ប្រក

អនុញ្ញាអោយលោក ឃុន ហាំង បើកស្ថានីយ៍ទូរទស្សន៍

កាណាល់ លេខ ៩

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម នស.រកម.០១៩៦.១៤ ចុះថ្ងៃទី ២៤.០១.៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតអនុញ្ញាតលេខ គ.ច.វិ ចុះថ្ងៃទី ០៧ . ០១ ៩៥

សំរេច

ប្រការ ១ : អនុញ្ញាតលោក **ឃុន ហាំង** ប្រធានក្រុមហ៊ុនសាជីវកម្មផ្សព្វផ្សាយកម្ពុជា បើកស្ថានីយ៍ទូរទស្សន៍ កាណាល់ លេខ ៩ អនុភាពកំលាំងផ្សាយតិចជាង ឬ អតិបរមា គ.វ និង កំពស់ អង់តែនត្រឹម ៩០ ម៉ែត្រ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍ទូរទស្សន៍នេះ ត្រូវគោរពតាមកិច្ចសន្យា និង ច្បាប់បញ្ញត្តិបទ បញ្ជារឬសេចក្ដីណែនាំ ខាងផ្នែកសោតទស្សន៍ទាំងឡាយនៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីមិនគោរពតាមប្រការ ២ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជា ណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយក ទូរទស្សន៍ជាតិកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និង អាជ្ញាធរដែល មានពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៥_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៦៦០ ពម អយក.ប្រក

ស្ដីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសំរាប់សិស្ស

«សិក្សាសង្គមថ្នាក់ទី ៦»

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល

- បានឃើញ ព្រះរាជក្រឹត្យ លេខ នស.រកត. ១០៩៤.៩០ ៣១. ខែ តុលា ឆ្នាំ ១៩៩៤ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស.រកម .០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញលិខិតឧទ្ទេសនាមលេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំយុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅ «សិក្សាសង្គម ថ្នាក់ទី ៦ » ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសំរាប់សិស្ស «សិក្សាសង្គមថ្នាក់ទី ៦ » ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការសិក្សាសង្គម បឋមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា រៀបរៀងដោយអ្នកស្រី **យិន ទ៉ានថា** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យ នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

តូល ឡោះ

* * *

៦_ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ប្រកាស

ប្រកាសលេខ ២០៧ ប្រក.សកប
ស្តីពីការបង្កើតការិយាល័យអាស៊ាន ចំណុះអគ្គនាយកដ្ឋាន
ទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន

* * *

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១.១១.១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១.១០.១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹតលេខ ៣២.អនក្រ.បក ចុះថ្ងៃទី ២៥.០៦.១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង

សំរេច

ប្រការ១ : ត្រូវបានបង្កើតការិយាល័យកិច្ចការអាស៊ាន **(ASEAN Urlit)** ចំណុះអគ្គនាយកដ្ឋានទីស្តីការក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រការ២ : ការិយាល័យកិច្ចការអាស៊ាន មានភារកិច្ចដូចតទៅ ÷

–វិភាគ និង គ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់ទៅនឹងសមត្ថកិច្ចរបស់ក្រសួង ។

–ធ្វើការសំរបសំរួល និង ទំនាក់ទំនងជាមួយស្ថាប័ននានា ព្រមទាំងជាមួយលេខាធិការដ្ឋាន ជាតិអាស៊ាន ដែលស្ថិតនៅក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ប្រការ ៣ : ការិយាល័យកិច្ចការ អាស៊ាន ដឹកនាំដោយប្រធានការិយាល័យមួយនាក់ និង មានមន្ត្រី រាជការតាមតំរូវការចាំបាច់ ។

ប្រការ ៤ : ឯកឧត្តម អគ្គនាយក លោកនាយកខុទ្ទកាល័យ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវ ទទួលបន្ទុកអនុវត្តន៍រៀងខ្លួន តាមខ្លឹមសារនៃប្រកាសនេះ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
ហត្ថលេខា និង ត្រា
អ៊ុង ហឿត

* * *

ក្បៀង ០០១៧ ទទឹង ៤ ធ្នូណា

ជ្រៃគ្រីះហយេះហេដ្ឋិបតិយ៍ឧបរេជាតិយ៍ះយោះ